**Lynn Community Health Center,** *269 Union Street Lynn, Mass 01901*
*មន្ត្រីឯកជន HIPAA 781-586-6652*



# ព័ត៌មានរបស់លោកអ្នក។ សិទ្ធិរបស់អ្នក។ ទំនួលខុសត្រូវរបស់យើងខ្ញុំ។

សេចក្តីជូនដំណឹងនេះរៀបរាប់អំពីរបៀបដែលព័ត៌មានវេជ្ជសាស្ត្រអំពីអ្នកអាចត្រូវបានប្រើប្រាស់ និងបង្ហាញ ព្រមទាំងរបៀបដែលអ្នកអាចចូលប្រើប្រាស់ព័ត៌មាននេះ។
**សូមពិនិត្យសេចក្តីជូនដំណឹងយ៉ាងប្រុងប្រយ័ត្ន។**

## សិទ្ធិរបស់អ្នក

**ចំពោះព័ត៌មានសុខភាពរបស់អ្នក អ្នកមានសិទ្ធិជាក់លាក់មួយចំនួន។** ផ្នែកនេះពន្យល់អំពីសិទ្ធិរបស់អ្នក និងទំនួលខុសត្រូវមួយចំនួនរបស់យើងខ្ញុំ ដើម្បីជួយលោកអ្នក។

| | |
|---|---|
| **ទទួលច្បាប់ចម្លងជាអេឡិចត្រូនិកឬជាក្រដាសនៃឯកសារវេជ្ជសាស្ត្ររបស់អ្នក** | • អ្នកអាចស្នើសុំជួប ឬទទួលច្បាប់ចម្លងនៃឯកសារវេជ្ជសាស្ត្ររបស់អ្នកបាននិងព័ត៌មានសុខភាពផ្សេងទៀតដែលយើងមានអំពីអ្នក។ សាកសួរយើងខ្ញុំអំពីរបៀបធ្វើវា។<br>• យើងខ្ញុំនឹងផ្តល់ជូនច្បាប់ចម្លង ឬសេចក្តីសង្ខេបអំពីសុខភាពរបស់អ្នក ជាទូទៅក្នុងរយៈ 30 ថ្ងៃក្រោយការស្នើសុំរបស់អ្នក។ យើងខ្ញុំអាចនឹងគិតថ្លៃសេវាតាមថ្លៃដើមក្នុងតម្លៃសមរម្យ។ |
| **ស្នើសុំឲ្យយើងខ្ញុំកែតម្រូវឯកសារវេជ្ជសាស្ត្ររបស់អ្នក** | • អ្នកអាចស្នើសុំឲ្យយើងខ្ញុំកែតម្រូវព័ត៌មានសុខភាពអំពីអ្នក ដែលអ្នកគិតថាឯកសារគឺមិនត្រឹមត្រូវ ឬមិនពេញលេញ។ សាកសួរយើងខ្ញុំអំពីរបៀបធ្វើវា។<br>• យើងខ្ញុំអាចនិយាយ "មិនយល់ព្រម" ចំពោះសំណើរបស់អ្នក ប៉ុន្តែយើងខ្ញុំនឹងប្រាប់អ្នកជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 60 ថ្ងៃ។ |
| **ស្នើសុំការទំនាក់ទំនងដោយលាក់ការសម្ងាត់** | • អ្នកអាចស្នើសុំឲ្យយើងខ្ញុំទាក់ទងមកអ្នកតាមវិធីជាក់លាក់បាន (ឧទាហរណ៍ ទូរសព្ទតាមគេហដ្ឋាន ឬការិយាល័យ) ឬផ្ញើសំបុត្រទៅកាន់អាសយដ្ឋានផ្សេងទៀត។<br>• យើងនឹងនិយាយ "យល់ព្រម" ចំពោះសំណើដែលសមហេតុផលទាំងអស់។ |

*បន្តទៅទំព័របន្ទាប់*



មន្ត្រីឯកជន HIPAA 781-586-6652

## សិទ្ធិរបស់អ្នក *បន្ត*

| | |
|---|---|
| **ស្នើសុំឲ្យយើងខ្ញុំកម្រិតនូវអ្វីដែលយើងប្រើប្រាស់ ឬ ចែករំលែក** | • អ្នកអាចស្នើសុំឲ្យយើងខ្ញុំ **មិនត្រូវ**ប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពជាក់លាក់សម្រាប់ការព្យាបាល ការបង់ប្រាក់ ឬប្រតិបត្តិការរបស់យើងបាន។<br>• យើងខ្ញុំមិនចាំបាច់យល់ព្រមនឹងសំណើរបស់អ្នកទេ ហើយយើងអាចនិយាយ "មិនយល់ព្រម" ប្រសិនបើវាអាចប៉ះពាល់ដល់ការថែទាំរបស់អ្នក។<br>• ប្រសិនបើអ្នកបង់ប្រាក់លើសេវាកម្ម ឬសម្ភារថែទាំសុខភាពដោយចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងតម្លៃពេញ អ្នកអាចស្នើសុំឲ្យយើងខ្ញុំមិនត្រូវចែករំលែកព័ត៌មាននោះសម្រាប់គោលបំណងបង់ប្រាក់ឬប្រតិបត្តិការរបស់យើងជាមួយអ្នកធានារ៉ាប់រងសុខភាពរបស់អ្នកបាន។<br>• យើងខ្ញុំនឹងនិយាយ "យល់ព្រម" លុះត្រាតែច្បាប់តម្រូវឲ្យយើងខ្ញុំចែករំលែកព័ត៌មាននោះ។ |
| **ទទួលបញ្ជីអំពីអ្នកដែលយើងខ្ញុំបានចែករំលែកព័ត៌មានជាមួយ** | • អ្នកអាចសាកសួររកបញ្ជី (គណនេយ្យ) អំពីពេលវេលាដែលយើងខ្ញុំបានចែករំលែកព័ត៌មានសុខភាពរបស់អ្នកក្នុងរយៈពេលប្រាំមួយឆ្នាំ មុនថ្ងៃដែលអ្នកសាកសួរ អ្នកដែលយើងបានចែករំលែកព័ត៌មានជាមួយ និងមូលហេតុបាន។<br>• យើងខ្ញុំនឹងរួមបញ្ចូលការបង្ហាញទាំងអស់ លើកលែងតែ ការព្យាបាល ការបង់ប្រាក់ និង ប្រតិបត្តិការថែទាំសុខភាព និងការបង្ហាញជាក់លាក់មួយចំនួន (ដូចជាការបង្ហាញណាមួយដែលអ្នកស្នើសុំឲ្យយើងខ្ញុំ (បង្កើត)។ យើងនឹងផ្តល់បញ្ជីគណនេយ្យមួយឆ្នាំដោយគតគិតថ្លៃ ប៉ុន្តែគិតថ្លៃសេវាតាមថ្លៃដើមក្នុងតម្លៃសមរម្យ ប្រសិនបើអ្នកស្នើសុំមួយទៀតក្នុងកំឡុងពេល 12 ខែ។ |
| **ទទួលបានច្បាប់ចម្លងនៃសេចក្តីជូនដំណឹងអំពីឯកជនភាព** | • អ្នកអាចស្នើសុំច្បាប់ចម្លងជាក្រដាសនៃសេចក្តីជូនដំណឹងនេះនៅពេលណាក៏បាន ទោះបីជាអ្នកយល់ព្រមទទួលសេចក្តីជូនដំណឹងនេះជាអេឡិចត្រូនិកក៏ដោយ។ យើងខ្ញុំនឹងផ្តល់ជូនច្បាប់ចម្លងជាក្រដាសជូនអ្នកភ្លាម |
| **ជ្រើសរើសនរណាម្នាក់ ដើម្បីតំណាងឲ្យអ្នក** | • ប្រសិនបើអ្នកបានប្រគល់លិខិតផ្ទេរអំណាចវេជ្ជសាស្ត្រទៅនរណាម្នាក់ ឬមាននរណាម្នាក់ជាអាណាព្យាបាលស្របច្បាប់របស់អ្នក បុគ្គលនោះអាចអនុវត្តសិទ្ធិរបស់អ្នក និងធ្វើការសម្រេចចិត្តអំពីសុខភាពរបស់អ្នកបាន។<br>• យើងនឹងប្រាកដថា បុគ្គលនោះមានសិទ្ធិនេះ ហើយអាចតំណាងឲ្យអ្នក មុនពេលយើងខ្ញុំចាត់វិធានការ ណាមួយ។ |
| **ដាក់ពាក្យបណ្តឹង ប្រសិនបើអ្នកគិតថាសិទ្ធិរបស់អ្នកត្រូវបានបំពាន** | • អ្នកអាចប្តឹងតវ៉ាបាន ប្រសិនបើអ្នកគិតថាយើងខ្ញុំបានបំពានសិទ្ធិរបស់អ្នក ដោយទាក់ទងមកយើងខ្ញុំដោយប្រើប្រាស់ព័ត៌មាននៅទំព័រទី 1 ។<br>• អ្នកអាចដាក់ពាក្យបណ្តឹងទៅនាយកដ្ឋានសុខាភិបាល និងសេវាមនុស្សសហរដ្ឋអាមេរិកសម្រាប់សិទ្ធិស៊ីវិលបាន ដោយផ្ញើលិខិតទៅ 200 Independence Avenue, S.W., Washington, D.C. 20201 ទូរសព្ទទៅ 1-877-696-6775 ឬចូលទៅ www.hhs.gov/ocr/privacy/hipaa/complaints/.<br>• យើងនឹងមិនតបតប្រឆាំងនឹងអ្នកចំពោះការដាក់ពាក្យបណ្តឹងឡើយ។ |



មន្ត្រីឯកជន HIPAA 781-586-6652

## ជម្រើសរបស់អ្នក

**សម្រាប់ព័ត៌មានសុខភាពជាក់លាក់មួយចំនួន អ្នកអាចប្រាប់យើងខ្ញុំអំពីជម្រើសរបស់អ្នកជុំវិញអ្វីដែលយើងចែករំលែកបាន។** ប្រសិនបើអ្នកមានចំណូលចិត្តច្បាស់លាស់ចំពោះរបៀបដែលយើងចែករំលែកព័ត៌មានរបស់អ្នកក្នុងស្ថានភាពដែលបានរៀបរាប់នៅខាងក្រោម ចូរពិភាក្សាជាមួយយើងខ្ញុំ។ ប្រាប់យើងខ្ញុំនូវអ្វីដែលអ្នកចង់ឲ្យយើងធ្វើ ហើយយើងខ្ញុំនឹងធ្វើតាមការណែនាំរបស់អ្នក។

| | |
|---|---|
| **ក្នុងករណីទាំងនេះ អ្នកមាន ទាំងសិទ្ធិ និងជម្រើសក្នុងការប្រាប់យើងខ្ញុំឲ្យ៖** | • ចែករំលែកព័ត៌មានជាមួយគ្រួសារ មិត្តភក្តិជិតស្និទ្ធរបស់អ្នក ឬអ្នកដែលពាក់ព័ន្ធផ្សេងទៀតក្នុងការថែទាំរបស់អ្នក។<br>• ចែករំលែកព័ត៌មាននៅក្នុងស្ថានភាពសង្គ្រោះពេលមានមហន្តរាយ។<br>• រួមបញ្ចូលព័ត៌មានរបស់អ្នកនៅក្នុងបញ្ជីឈ្មោះក្នុងមន្ទីរពេទ្យ។<br>• ទាក់ទងអ្នកចំពោះលទ្ធភាពរៃអង្គាសមូលនិធិ។<br><br>*ប្រសិនបើអ្នកមិនអាចប្រាប់យើងខ្ញុំអំពីចំណូលចិត្តរបស់អ្នកបានទេ ឧទាហរណ៍ ប្រសិនបើអ្នកសន្លប់បាត់ស្មារតី យើងខ្ញុំអាចនឹងបន្តអនុវត្ត ហើយចែករំលែកព័ត៌មានរបស់អ្នក ប្រសិនបើយើងជឿថា វាគឺជាឧត្តមប្រយោជន៍របស់អ្នក។ យើងក៏អាចនឹងចែករំលែកព័ត៌មានរបស់អ្នកផងដែរ នៅពេលចាំបាច់ត្រូវកាត់បន្ថយការគំរាមកំហែងធ្ងន់ធ្ងរ ឬប្រុងនឹងកើតមានឡើងដល់សុខភាព ឬសុវត្ថិភាព។* |
| **ក្នុងករណីទាំងនេះ យើងខ្ញុំ *មិនដែល* ចែករំលែកព័ត៌មានរបស់អ្នកទេ លុះត្រាតែអ្នកផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរមកយើងខ្ញុំ៖** | • គោលបំណងធ្វើទីផ្សារ។<br>• ការលក់ព័ត៌មានរបស់អ្នក។<br>• ការចែករំលែកភាគច្រើននៃកំណត់សម្គាល់អំពីការព្យាបាលភាពវិកលចរិត។ |
| **ក្នុងករណីរៃអង្គាសប្រាក់៖** | • យើងខ្ញុំអាចទាក់ទងអ្នកសម្រាប់លទ្ធភាពរៃអង្គាសប្រាក់ ប៉ុន្តែអ្នកអាចប្រាប់យើងខ្ញុំមិនឲ្យទាក់ទងមកអ្នកម្តងទៀតបាន។ |

## ការប្រើប្រាស់ និងការបង្ហាញរបស់យើងខ្ញុំ

**តើយើងខ្ញុំជាទូទៅប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកដោយរបៀបណា?** ជាទូទៅ យើងខ្ញុំប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកតាមរបៀបដូចខាងក្រោម។

| | | |
|---|---|---|
| **ការព្យាបាលលោកអ្នក** | • យើងខ្ញុំអាចប្រើប្រាស់ព័ត៌មានសុខភាពរបស់អ្នក និងចែករំលែកវាជាមួយវេជ្ជបណ្ឌិតជំនាញផ្សេងទៀតដែលកំពុងព្យាបាលអ្នក។ | *ឧទាហរណ៍ វេជ្ជបណ្ឌិតដែលព្យាបាលរបួសឲ្យអ្នកសាកសួរវេជ្ជបណ្ឌិតផ្សេងទៀតអំពីស្ថានភាពសុខភាពជារួមរបស់អ្នក។* |
| **ការដំណើរការស្ថាប័នរបស់យើងខ្ញុំ** | • យើងខ្ញុំអាចប្រើប្រាស់ និងចែករំលែកព័ត៌មានសុខភាពរបស់អ្នកដើម្បីដំណើរការអនុវត្តរបស់យើងខ្ញុំ កែលម្អការថែទាំរបស់អ្នក និងទាក់ទងអ្នកនៅពេលចាំបាច់។ | *ឧទាហរណ៍៖ យើងខ្ញុំប្រើប្រាស់ព័ត៌មានសុខភាពអំពីអ្នកដើម្បីគ្រប់គ្រងការព្យាបាលនិងសេវាកម្មរបស់អ្នក។* |
| **ការចេញវិក្កយបត្រសម្រាប់សេវាកម្មរបស់អ្នក** | • យើងខ្ញុំអាចប្រើប្រាស់ និងចែករំលែកព័ត៌មានសុខភាពរបស់អ្នក ដើម្បីចេញវិក្កយបត្រ និងទទួលបានការបង់ប្រាក់ពីផែនការសុខភាព ឬអង្គភាពផ្សេងទៀត។ | *ឧទាហរណ៍៖ យើងខ្ញុំផ្តល់ព័ត៌មានអំពីអ្នកទៅកាន់ផែនការធានារ៉ាប់រងសុខភាពរបស់អ្នកដូច្នេះអង្គភាពនោះនឹងបង់ប្រាក់សម្រាប់សេវាកម្មរបស់អ្នក។* |

*បន្តទៅទំព័របន្ទាប់*

**តើយើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកតាមវិធីផ្សេងទៀតដោយរបៀបណា?** យើងត្រូវបានអនុញ្ញាត ឬតម្រូវឲ្យចែករំលែកព័ត៌មានរបស់អ្នកតាមវិធីផ្សេងទៀត — ជាទូទៅតាមវិធីដែលចូលរួមចំណែកដល់ផលប្រយោជន៍សាធារណៈ ដូចជាសុខភាពសាធារណៈ និងការស្រាវជ្រាវ។ យើងខ្ញុំត្រូវតែបំពេញតាមលក្ខខណ្ឌជាច្រើនរបស់ច្បាប់ មុនពេលយើងខ្ញុំអាចចែករំលែកព័ត៌មានរបស់អ្នកសម្រាប់គោលបំណងទាំងនេះបាន។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖
**www.hhs.gov/ocr/privacy/hipaa/understanding/consumers/index.htm**

| | |
|---|---|
| **ជំនួយជាមួយនឹងបញ្ហាសុខភាពសាធារណៈ និងសុវត្ថិភាព** | យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពអំពីអ្នកសម្រាប់ស្ថានភាពជាក់លាក់មួយចំនួនដូចជា៖<br>• ការបង្ការជំងឺ។<br>• ជំនួយជាមួយនឹងការហៅផលិតផលត្រឡប់មកវិញ។<br>• ការរាយការណ៍ប្រតិកម្មអាក្រក់ដោយការប្រើថ្នាំ<br>• ការរាយការណ៍ការរំលោភបំពាន ការមិនអើពើ ឬអំពើហិង្សាក្នុងគ្រួសារដែលសង្ស័យ។<br>• ការបង្ការ ឬការកាត់បន្ថយការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព ឬសុវត្ថិភាពរបស់អ្នកនរណាម្នាក់។ |
| **ធ្វើការស្រាវជ្រាវ** | • យើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នកសម្រាប់ការស្រាវជ្រាវសុខភាព។ |
| **អនុលោមតាមច្បាប់** | • យើងខ្ញុំនឹងចែករំលែកព័ត៌មានអំពីអ្នក ប្រសិនបើច្បាប់រដ្ឋ ឬសហព័ន្ធត្រូវការព័ត៌មាននោះ រួមទាំងនាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស ប្រសិនបើនាយកដ្ឋានចង់ឃើញថាតើយើងកំពុងអនុលោមតាមច្បាប់ឯកជនភាពរបស់សហព័ន្ធដែរឬអត់។ |
| **ឆ្លើយតបទៅនឹងសំណើបរិច្ចាគសរីរាង្គ និងជាលិកា** | • យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពអំពីអ្នកជាមួយនឹងស្ថាប័នផ្គត់ផ្គង់សរីរាង្គបាន។ |
| **ធ្វើការជាមួយអ្នកពិនិត្យវេជ្ជសាស្ត្រ ឬនាយកវិភាគសាកសព** | • យើងអាចចែករំលែកព័ត៌មានសុខភាពជាមួយអ្នកវិភាគសាកសព អ្នកពិនិត្យវេជ្ជសាស្ត្រ ឬនាយកវិភាគសាកសព នៅពេលមានមនុស្សស្លាប់។ |
| **ដោះស្រាយសំណងរបស់កម្មករ ការអនុវត្តច្បាប់ និងសំណើផ្សេងទៀតរបស់រដ្ឋាភិបាល** | • យើងអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពអំពីអ្នកបាន៖<br>• សម្រាប់ការទាមទារសំណងរបស់កម្មករ<br>• សម្រាប់គោលបំណងអនុវត្តច្បាប់ ឬជាមួយមន្ត្រីអនុវត្តច្បាប់<br>• ជាមួយភ្នាក់ងារត្រួតពិនិត្យសុខភាពសម្រាប់សកម្មភាពដែលអនុញ្ញាតដោយច្បាប់<br>• សម្រាប់មុខងារចាំបាច់របស់រដ្ឋាភិបាល ដូចជា យោធា សន្តិសុខជាតិ និងសេវាកម្មការពារប្រធានាធិបតី |
| **ការឆ្លើយតបទៅនឹងបណ្តឹង និងវិធានការតាមផ្លូវច្បាប់** | • យើងអាចចែករំលែកព័ត៌មានសុខភាពអំពីអ្នកឆ្លើយតបទៅនឹងតុលាការ ឬបទបញ្ជារដ្ឋបាល ឬឆ្លើយតបទៅនឹងដីកាបង្គាប់។ |

*ព័ត៌មានរសើប៖ Lynn Community Health Center. នឹងមិនបង្ហាញព័ត៌មានវេជ្ជសាស្ត្ររសើបណាមួយទាក់ទងនឹងលទ្ធផល/ការព្យាបាលមេរោគអេដស៍/ជំងឺអេដស៍ សុខភាពឥរិយាបថ/សុខភាពផ្លូវចិត្ត អំពើហិង្សាក្នុងគ្រួសារការធ្វើតេស្តសេនេទិច ជំងឺកាមរោគ ការរលូតកូន ការសេពគ្រឿងស្រវឹង/គ្រឿងញៀន ការរំលោភសេពសន្ថវៈ/ការប្រទូសរ៉ាយកេរ្តិ៍ភេទ និងការរំលោភបំពានលើកុមារ/មនុស្សចាស់/ជនពិការ ដោយមិនមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកឡើយ។*

## ទំនួលខុសត្រូវរបស់យើងខ្ញុំ

- ច្បាប់តម្រូវឲ្យយើងខ្ញុំរក្សាឯកជនភាព និងសន្តិសុខនៃព័ត៌មានសុខភាពដែលបានការពាររបស់អ្នក។
- យើងខ្ញុំនឹងឲ្យអ្នកដឹងភ្លាមៗ ប្រសិនបើមានការបំពានកើតឡើង ដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់ឯកជនភាព ឬ សន្តិសុខនៃព័ត៌មានរបស់អ្នក។
- យើងខ្ញុំត្រូវធ្វើតាមភារកិច្ច និងការអនុវត្តឯកជនភាពដែលបានរៀបរាប់នៅក្នុងសេចក្តីជូនដំណឹងនេះ និងឲ្យច្បាប់ចម្លងមួយដល់អ្នក។
- យើងនឹងមិនប្រើប្រាស់ ឬចែករំលែកព័ត៌មានផ្សេងទៀតរបស់អ្នកក្រៅពីអ្វីដែលបានរៀបរាប់នៅទីនេះ លុះត្រាតែអ្នកប្រាប់យើងខ្ញុំថា យើងអាចប្រើព័ត៌មានបានជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអ្នកប្រាប់យើងខ្ញុំថា យើងអាចប្រើព័ត៌មានបាន អ្នកអាចផ្លាស់ប្តូរការសម្រេចចិត្តរបស់អ្នកនៅពេលណាក៏បាន។ អនុញ្ញាតឲ្យយើងខ្ញុំដឹងជាលាយលក្ខណ៍អក្សរ ប្រសិនបើអ្នកផ្លាស់ប្តូរការសម្រេចចិត្តរបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ **www.hhs.gov/ocr/privacy/hipaa/understanding/consumers/noticepp.html.**

### ការផ្លាស់ប្តូរលក្ខខណ្ឌនៃសេចក្តីជូនដំណឹងនេះ

យើងខ្ញុំអាចផ្លាស់ប្តូរលក្ខខណ្ឌនៃសេចក្តីជូនដំណឹងនេះ ហើយការផ្លាស់ប្តូរនឹងអនុវត្តចំពោះព័ត៌មានទាំងអស់ដែលយើងមានអំពីអ្នក។ សេចក្តីជូនដំណឹងថ្មីនឹងអាចប្រើប្រាស់បាន ក្រោយពេលស្នើសុំ នៅតាមការិយាល័យរបស់យើង និងនៅលើគេហទំព័ររបស់យើង។

*បានកែប្រែ ខែមិថុនា ឆ្នាំ 2020 www.lchcnet.org*

**សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាពនេះ អនុវត្តចំពោះស្ថាប័នដូចខាងក្រោម។**

*LCHC គឺសមាជិកមួយនៃការរៀបចំការថែទាំសុខភាពដែលបានរួបរួមឡើង (OCHIN)។ ស្ថាប័នជាសមាជិកផ្សេងទៀតអាចរកបាននៅត្រង់នេះ https://ochin.org/member-portal/ochin-members/។ ការចូលប្រើប្រាស់ឯកសារអ្នកជំងឺ LCHC ដោយមិនមានការអនុញ្ញាតគឺត្រូវបានបន្តតាមដាន។*

*Lynn Community Health Center គឺជាផ្នែកមួយនៃការរៀបចំការថែទាំសុខភាពដែលបានរួបរួមគ្នាឡើង រួមមានអ្នកចូលរួមនៅក្នុង OCHIN ។ បញ្ជីបច្ចុប្បន្នរបស់អ្នកចូលរួម OCHIN មាននៅ www.ochin.org ដែលជាសហការីជំនួញរបស់ Lynn Community Health Center OCHIN ផ្គត់ផ្គង់បច្ចេកវិទ្យាព័ត៌មាន និងសេវាកម្មពាក់ព័ន្ធដល់ Lynn Community Health Center និងអ្នកចូលរួម OCHIN ផ្សេងទៀត។ OCHIN ក៏ពាក់ព័ន្ធក្នុងការវាយតម្លៃ គុណភាព និងការកែលម្អសកម្មភាពជំនួសឲ្យអ្នកចូលរួមរបស់ខ្លួនផងដែរ។ ឧទាហរណ៍ OCHIN សម្របសម្រួលសកម្មភាពត្រួតពិនិត្យគ្លីនិកជំនួសឲ្យស្ថាប័នដែលចូលរួមក្នុងការបង្កើត ការអនុវត្តស្តង់ដារ និងការវាយតម្លៃអត្ថប្រយោជន៍គ្លីនិកល្អបំផុតដែលអាចទទួលបានមកពីការប្រើប្រាស់ ប្រព័ន្ធឯកសារសុខភាពអេឡិចត្រូនិក។ OCHIN ក៏ជួយអ្នកចូលរួមឲ្យធ្វើការប្រកបដោយការសហការក្នុងការកែលម្អការគ្រប់គ្រងការបញ្ជូនអ្នកជំងឺក្នុង និងក្រៅផងដែរ។ ព័ត៌មានសុខភាពផ្ទាល់ខ្លួន របស់អ្នកអាចនឹងត្រូវបានចែករំលែកដោយ Lynn Community Health Center ជាមួយអ្នកចូលរួម OCHIN ផ្សេងទៀត ឬការផ្លាស់ប្តូរព័ត៌មានសុខភាពប៉ុណ្ណោះ នៅពេលចាំបាច់សម្រាប់ការព្យាបាលវេជ្ជសាស្ត្រ ឬសម្រាប់គោលបំណងប្រតិបត្តិការថែទាំសុខភាពនៃការរៀបចំការថែទាំសុខភាពដែលបានរួបរួមឡើង។ ប្រតិបត្តិការថែទាំសុខភាពអាចរួមបញ្ចូលរឿងផ្សេងទៀតដូចជា ការធ្វើជីអូកូដទីតាំងគេហដ្ឋានរបស់អ្នក ដើម្បីកែលម្អអត្ថប្រយោជន៍គ្លីនិកដែលអ្នកទទួលបាន។ ព័ត៌មានសុខភាពផ្ទាល់ខ្លួនអាចរួមបញ្ចូល ព័ត៌មានវេជ្ជសាស្ត្រអតីតកាល បច្ចុប្បន្ន និងអនាគត ក៏ដូចជាព័ត៌មានដែលបានបង្ហាញនៅក្នុងវិធានឯកជនភាពដែរ។ ព័ត៌មាននឹងត្រូវបានបង្ហាញស្របទៅតាមវិធានឯកជនភាព ឬច្បាប់ជាធរមានដែលបានកែប្រែពីពេលមួយទៅពេល*

*មួយ។ អ្នកមានសិទ្ធិក្នុងការផ្លាស់ប្តូរការសម្រេចចិត្តរបស់អ្នក និងដកការអនុញ្ញាតនេះ ប៉ុន្តែព័ត៌មានអាចនឹងផ្តល់រួចហើយ នៅពេលអនុញ្ញាតដោយអ្នក។ ការអនុញ្ញាតនឹងនៅមានប្រសិទ្ធភាពរហូតដល់ត្រូវបានលុបចោលវិញដោយអ្នកជាលាយលក្ខណ៍អក្សរ។ ប្រសិនបើបានស្នើសុំរួច អ្នកនឹងត្រូវបានផ្តល់បញ្ជីអង្គភាពមួយចំពោះព័ត៌មានរបស់អ្នកដែលត្រូវបានបង្ហាញ។*